# សក្ដានុពលរបស់អ្នក ឯកសិទ្ធិរបស់អ្នក

ប្រធាន ឌៀថើរ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ

*នៅពេលអ្នកអានគម្ពីរ និងស្ដាប់ ពាក្យសម្ដីរបស់ពួកព្យាការីដោយអស់ពីដួងចិត្តរបស់អ្នក និងគំនិត នោះព្រះអម្ចាស់នឹងប្រាប់អ្នក អំពីរបៀបដើម្បីរស់នៅតាមឯកសិទ្ធិបព្វជិតភាពរបស់អ្នក ។*

គ្រាមួយ មានបុរសម្នាក់សុបិនប៉ងចង់ដើរតាមនាវាកម្សាន្តមួយ ហើយនាវានោះចេញទៅសមុទ្រ មេឌីទែរ៉ាណេ ។ គាត់សុបិនប៉ងចង់ដើរនៅតាមផ្លូវទីក្រុងរ៉ូម ទីក្រុងអាធេនស៍ និងទីក្រុងអាស្តេនប៊ុល ។ គាត់បានសន្សំប្រាក់គ្រប់សេន រហូតទាល់តែគាត់មានប្រាក់គ្រប់គ្រាន់សម្រាប់ការធ្វើដំណើរតាមសមុទ្រ ។ ដោយសារគាត់គ្មានប្រាក់គ្រប់គ្រាន់ គាត់បានយកវ៉ាលីបន្ថែមមួយ ទៀតដែលមានដាក់សណ្ដែកកំប៉ុង នំប្រៃ ម្សៅទឹកក្រូច នោះគឺជាអ្វីដែលគាត់បរិភោគជារៀងរាល់ថ្ងៃ ។

គាត់ប្រហែលជាចង់ចូលរួមក្នុងសកម្មភាពជាច្រើន ដែលមាននៅលើនាវានោះ ដូចជា — ការហាត់ប្រាណនៅក្លឹបកីឡា ការលេងកូនគោល និងការហែលទឹកក្នុងអាង ។ គាត់ច្រណែននឹងអ្នកទាំងឡាយ ដែលទៅមើលកុន មើលការសម្ដែង និងការសម្ដែងខាងវប្បធម៌ ។ ហើយ គាត់ប្រាថ្នាយ៉ាងខ្លាំងចង់ភ្លក់ម្ហូបពិសេសៗ ដែលគាត់ឃើញនៅលើនាវា — អាហារគ្រប់មុខ បង្ហាញជាពិធីជប់លៀង ! ប៉ុន្តែបុរសម្នាក់នេះ ចង់ចំណាយប្រាក់តិចបំផុត រហូតធ្វើឲ្យគាត់មិនបានចូលរួមនៅក្នុងសកម្មភាពនេះឡើយ ។ គាត់អាចមើលទីក្រុងដែលគាត់ចង់ឃើញ ប៉ុន្តែភាគច្រើននៃការធ្វើដំណើរ គាត់នៅតែក្នុងកន្លែងរបស់គាត់ ហើយបរិភោគអាហារក្រៀមរបស់គាត់ប៉ុណ្ណោះ ។

នៅថ្ងៃចុងក្រោយនៃការដើរកម្សាន្តតាមនាវានេះ សមាជិកក្រុមនាវា បានសួរគាត់ថា តើពិធីជប់លៀងលាគ្នាណាមួយដែលគាត់ចង់ចូលរួម ។ពេលនោះហើយទើបគាត់ដឹងដឹងថា មិនមែនតែ ពិធីជប់លៀងលាគ្នាប៉ុណ្ណោះទេដែលគាត់អាចចូលរួមបាន ប៉ុន្តែគាត់ក៏អាចចូលរួមស្ទើរតែគ្រប់សកម្មភាពនៅលើនាវាកម្សាន្ត ដូចជា — អាហារ ការលេងកម្សាន្ត គ្រប់សកម្មភាព — ដោយសារសកម្មភាពទាំងនេះត្រូវបានគិតថ្លៃនៅក្នុង សំបុត្ររបស់គាត់រួចទៅហើយ ។ បុរសនេះបានដឹងយឺតពេលហើយ ថាគាត់មិនបានទទួលនូវអ្វីៗតាមឯកសិទ្ធិរបស់គាត់ឡើយ ។

មានសំណួរនៅក្នុងរឿងប្រៀបធៀបនេះ ៖ ក្នុងនាមជាអ្នកកាន់បព្វជិតភាព តើយើងកំពុងតែមិនរស់នៅតាមឯកសិទ្ធិរបស់យើងមែនទេ នៅពេលយើងមានឱកាស និងសិទ្ធិទទួលអំណាចពិសិដ្ឋ អំណោយទាននានា និងពរជ័យទាំងឡាយ ក្នុងនាមជាអ្នកកាន់បព្វជិតភាពរបស់ព្រះនោះ ?

### *សិរីល្អ និងភាពអស្ចារ្យនៃបព្វជិតភាព*

យើងគ្រប់គ្នាបានដឹងថា បព្វជិតភាពមានន័យខ្ពស់ជាងឈ្មោះ ឬ ចំណងជើង ។ ព្យាការីយ៉ូសែប ស៊្មីធបានបង្រៀនថា « បព្វជិតភាព គឺជាគោលការណ៍ដ៏អស់កល្ប ហើយមាននៅជាមួយព្រះ ...ពីភាពអស់កល្ប រហូតដល់ភាពអស់កល្ប ដោយគ្មានថ្ងៃចាប់ផ្ដើម ឬឆ្នាំបញ្ចប់ទេ » ។[1] បព្វជិតភាពមាន « កូនសោនៃចំណេះវិជ្ជាពីព្រះ » ។[2] តាមពិត តាមរយៈបព្វជិតភាព « អំណាចរបស់ព្រះទាំងអស់ត្រូវបានបើកសម្ដែង » ។[3]

ពរជ័យនៃបព្វជិតភាព មានហួសពីលទ្ធភាពរបស់យើងអាចយល់បាន ។ អ្នកកាន់បព្វជិតភាពមិលគីស្សាដែកស្មោះត្រង់ អាច « ក្លាយជាពួករើសតាំងនៃព្រះ ... » ។[4] ពួកគេ « ត្រូវបានញែកជាបរិសុទ្ធ ដោយសារព្រះវិញ្ញាណចំពោះការសាងរូបកាយរបស់ពួកគេជាថ្មី » ។[5] និងអាចនៅទីបំផុតទទួល « អ្វីៗគ្រប់យ៉ាង ដែលព្រះវរបិតាមាន »[6] នេះពិបាកយល់ក្តី ប៉ុន្តែវាស្រស់ស្អាត ហើយខ្ញុំថ្លែងទីបន្ទាល់ថា វាគឺជាការពិត ។

កត្តាដែលព្រះវរបិតាសួគ៌របស់យើង ប្រគល់អំណាច និងការទទួលខុសត្រូវនេះដល់បុរសគឺជាភស្តុតាងនៃសេចក្ដីស្រឡាញ់ដ៏មហិមារបស់ទ្រង់ចំពោះយើង និងប្រាប់ជាមុនអំពីសក្ដានុពលរបស់យើង ក្នុងនាមជាបុត្រារបស់ព្រះក្នុងជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ។

ប៉ុន្តែ ជាញឹកញាប់ សកម្មភាពរបស់យើងប្រាប់ថា យើងរស់នៅក្រោមយ៉ាងឆ្ងាយពីសក្ដានុពលនេះ ។ នៅពេលសួរអំពីបព្វជិតភាព យើងជាច្រើន អាចសូត្រនិយមន័យត្រឹមត្រូវ ប៉ុន្តែនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងអាចនឹងបង្ហាញថា ការយល់ដឹងយើងមានកម្រិតលើសពីការហាត់សរសេរបន្តិចប៉ុណ្ណោះ ។

បងប្អូនប្រុស យើងប្រឈមមុខនឹងជម្រើសមួយ ។ យើងអាចពេញចិត្តចំពោះបទពិសោធន៍ ចុះអន់ថយជាអ្នកកាន់បព្វជិតភាពទាំងឡាយ ហើយយល់ស្របចំពោះបទពិសោធន៍យ៉ាងឆ្ងាយក្រោមនៃឯកសិទ្ធិរបស់យើង ។ ឬយើងអាចទទួលទាននិកាសខាងវិញ្ញាណដ៏សម្បូរហូរហៀរ និងពរជ័យនៃបព្វជិតភាពជាសាកល ។

### *តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរស់នៅតាមសក្ដានុពលរបស់យើង ?*

ពាក្យដែលត្រូវបានសរសេរក្នុងគម្ពីរ និងនិយាយនៅក្នុងសន្និសីទទូទៅមក « ប្រដូចនឹងខ្លួនយើង » ពុំមែនសម្រាប់តែការអាន និងការស្ដាប់ប៉ុណ្ណោះទេ ។[7] ជាញឹកញាប់ យើងចូលរួមការប្រជុំ ហើយងក់ក្បាល យើងប្រហែលជាញញឹមដោយការដឹង និងការយល់ស្រប ។ យើងកត់ចំណាំ ហើយយើងប្រហែលជានិយាយមកខ្លួនឯងថា « នោះជាអ្វីដែលខ្ញុំនឹងធ្វើ » ។ ប៉ុន្តែបន្ទាប់ពីបានស្ដាប់ឮ ការសរសេររំឭកនៅក្នុងទូរស័ព្ទ និងការធ្វើជាក់ស្ដែង « ការអនុវត្តន៍ » របស់យើងបានផ្លាស់ប្ដូរទៅកន្លែង « ថ្ងៃក្រោយ » វិញ ។ បងប្អូនប្រុស សូមប្រាកដថា ដាក់ « ការអនុវត្តន៍ » របស់យើង ផ្លាស់ទៅកន្លែង « ធ្វើឥឡូវនេះវិញ » !

នៅពេលអ្នកអានគម្ពីរ និងស្ដាប់ ពាក្យសម្ដីរបស់ពួកព្យាការីដោយអស់ពីដួងចិត្តរបស់អ្នក និងគំនិត នោះព្រះអម្ចាស់នឹងប្រាប់អ្នក អំពីរបៀបដើម្បីរស់នៅតាមឯកសិទ្ធិបព្វជិតភាពរបស់អ្នក ។ ចូរកុំទុកឲ្យមួយថ្ងៃណារំលងទៅដោយមិនបានធ្វើអ្វីមួយ ដើម្បីធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណឡើយ ។

### **ទីមួយ ៖ អានក្បួនម្ចាស់**

បើសិនជាអ្នកមានកុំព្យូទ័រទំនើប ហើយថ្លៃបំផុតរបស់ពិភពលោក តើអ្នកនឹងប្រើវាគ្រាន់តែលំអតុមែនទេ ? កុំព្យូទ័រប្រហែលជាមើលទៅគួរឲ្យចាប់អារម្មណ៍ ។ វាអាចមាននូវសក្ដានុពលគ្រប់ប្រភេទ ។ ប៉ុន្តែនៅពេលដែលអ្នកសិក្សាតាមក្បួន ដោយរៀនអំពីរបៀបប្រើកម្មវិធី ហើយបើកភ្លើងប៉ុណ្ណោះ ទើបអ្នកអាចប្រើសក្ដានុពលដ៏ពេញលេញនោះ ។

បព្វជិតភាពបរិសុទ្ធរបស់ព្រះក៏មានក្បួននៃម្ចាស់របស់វាផងដែរ ។សូមឲ្យយើងតាំងចិត្តអានព្រះគម្ពីរ និងក្បួនខ្នាតដោយមានគោលបំណង និងផ្ដោតយកចិត្តទុកដាក់ ។ សូមយើងចាប់ផ្ដើមអានឡើងវិញនូវកណ្ឌ 20, 84, 107 និង 121 ក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាឡើងវិញ ។ កាលណា យើងកាន់តែសិក្សាពីគោលបំណង សក្ដានុពល និងការអនុវត្តន៍នៃការប្រើប្រាស់បព្វជិតភាព នោះយើងនឹងស្ញើចសរសើរកាន់តែខ្លាំងចំពោះអំណាចរបស់វា ហើយព្រះវិញ្ញាណនឹងបង្រៀនយើងពីរបៀបទទួលបាន ហើយប្រើអំណាចនោះដើម្បីប្រទានពរដល់ក្រុមគ្រួសារ សហគមន៍ និងសាសនាចក្រ ។

ក្នុងនាមជាប្រជាជនមួយក្រុម យើងដាក់អាទិភាពខ្ពស់ទៅលើការរៀនសូត្រខាងលោកិយ និងការអភិវឌ្ឍន៍វិជ្ជាជីវៈដោយត្រឹមត្រូវ ។ យើងចង់ ហើយយើងត្រូវតែធ្វើឲ្យល្អវិសេសក្នុងមុខវិជ្ជា និងហត្ថកោសល្យ ។ ខ្ញុំសូមសរសើរដល់អ្នកដែលខិតខំដោយឧស្សាហ៍ព្យាយាម ដើម្បីទទួលការអប់រំ ហើយមានជំនាញនៅក្នុងវិស័យរបស់អ្នក ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យមានជំនាញនៅក្នុងគោលលទ្ធិនៃដំណឹងល្អផងដែរ ---ជាពិសេស គោលលទ្ធិនៃបព្វជិតភាព ។

យើងរស់នៅក្នុងជំនាន់មួយដែលខគម្ពីរ និងពាក្យពេចន៍នៃពួកសាវក និងព្យាការីសម័យទំនើបអាចទទួលបានយ៉ាងងាយស្រួលជាងគ្រាណាៗទាំងអស់នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។ ប៉ុន្តែ វាគឺជាឯកសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់យើង ដើម្បីឈោងទៅ ហើយចាប់ការបង្រៀនរបស់វា ។ គោលការណ៍ និងគោលលទ្ធិទាំងឡាយនៃបព្វជិតភាព គឺល្អ ហើយខ្ពង់ខ្ពស់ក្រៃលែង ។ កាលណា យើងកាន់តែសិក្សាពី គោលលទ្ធិ និងសក្ដានុពល ហើយអនុវត្តគោលបំណងដ៏មានប្រយោជន៍នៃបព្វជិតភាព ព្រលឹងរបស់យើងនឹងត្រូវបានលូតលាស់ឡើង ការយល់ដឹងរបស់យើងនឹងចម្រើនឡើង ហើយយើងនឹងមើលឃើញនូវអ្វីដែលព្រះអម្ចាស់បានរៀបចំសម្រាប់យើង ។

### **ទីពីរ ៖ ស្វែងរកវិវរណៈតាមព្រះវិញ្ញាណ**

ទីបន្ទាល់អំពីព្រះយេស៊ូវ និងដំណឹងល្អដែលបានស្ដារឡើងវិញរបស់ទ្រង់គឺតម្រូវលើសពីចំណេះដឹងទៅទៀត --- វាតម្រូវឲ្យមានវិវរណៈផ្ទាល់ខ្លួនដែលបានបញ្ជាក់ដោយការអនុវត្តន៍គោលការណ៍ទាំងឡាយនៃដំណឹងល្អដ៏ទៀងត្រង់ និងដោយមានការលះបង់ ។ ព្យាការីយ៉ូសែប ស្ម៊ីធ បានពន្យល់ថា បព្វជិតភាពគឺ « ជាបណ្ដាញដែលព្រះដ៏មានមហិទ្ធិឫទ្ធិ បានចាប់ផ្ដើមបើកសម្ដែងសិរីល្អរបស់ទ្រង់ នៅគ្រានៃការបង្កបង្កើតផែនដីនេះពីដំបូង ហើយដែលទ្រង់បានបន្តបើកសម្ដែងព្រះអង្គទ្រង់ទៅដល់កូនចៅមនុស្សរហូតដល់ពេលបច្ចុប្បន្ន » ។[8]

បើសិនជាយើងមិនចង់ប្រើផ្លូវនៃវិវរណៈនេះទេ យើងកំពុងតែរស់នៅក្រោមពីឯកសិទ្ធិនៃបព្វជិតភាពរបស់យើងហើយ ។ ឧទាហរណ៍ មានអ្នកជឿ ប៉ុន្តែមិនដឹងថាពួកគេជឿឡើយ ។ ពួកគេបានទទួលចម្លើយផ្សេងៗគ្នា តាមសម្លេងតូចរហៀងអស់រយៈពេលយ៉ាងយូរ ប៉ុន្តែដោយសារការបំផុសគំនិតនេះហាក់ដូចជាតូចពេក ហើយមិនសូវសំខាន់ នោះពួកគេមិនទទួលស្គាល់ថាវាគឺជាវិវរណៈនោះឡើយ ។ ជាលទ្ធផលពួកគេបានអនុញ្ញាតឲ្យការសង្ស័យរារាំងពួកគេពីការបំពេញសក្ដានុពលរបស់ពួកគេ ក្នុងនាមជាអ្នកកាន់បព្វជិតភាព ។

វិវរណៈ និងទីបន្ទាល់ ពុំតែងតែកើតមានដោយកម្លាំងដ៏អស្ចារ្យជានិច្ចនោះទេ ។ សម្រាប់មនុស្សជាច្រើន ទីបន្ទាល់កើតឡើងយឺតៗ --- មួយចំណែកម្ដងៗ ។ ពេលខ្លះវាកើតមកបន្តិចម្ដងៗដែលវាពិបាកនឹកចាំនូវគ្រាណាពិតប្រាកដដែលយើងដឹងថាដំណឹងល្អនេះពិត ។ ព្រះអម្ចាស់ប្រទានដល់យើង « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច » ។ [9]

ពេលខ្លះ ទីបន្ទាល់យើងគឺដូចជាដុំព្រិល ដែលរីកកាន់តែធំឡើងៗនៅពេលយើងរមូលវា ។ យើងចាប់ផ្ដើមដោយពន្លឺតូចមួយ --គ្រាន់តែជាបំណងដើម្បីជឿ ។ « ពន្លឺនៅជាប់នឹងពន្លឺ » ដោយយឺតៗ [10] ហើយ « អ្នកណាដែលទទួលពន្លឺ ហើយនៅជាប់ក្នុងព្រះ នោះទទួលពន្លឺថែមទៀត ហើយពន្លឺនោះភ្លឺកាន់តែខ្លាំងឡើងៗ រហូតដល់ថ្ងៃបានល្អឥតខ្ចោះ » [11] នៅពេល « នៅវេលាកំណត់ [ យើង ] បានទទួលនូវភាពពោរពេញរបស់ទ្រង់ » ។ [12]

ចូរគិតថាវាជារឿងដ៏រុងរឿងយ៉ាងណាដើម្បីឈោងទៅហួសពីការកំណត់ខាងលោកិយរបស់យើង ដើម្បីឲ្យភ្នែកនៃយោបល់របស់យើងបើកឡើង ហើយទទួលពន្លឺ និងចំណេះវិជ្ជាមកពីប្រភពសេឡេស្ទាលនោះ ! វាគឺជាឯកសិទ្ធិ និងជាឱកាសរបស់យើងក្នុងនាមជាអ្នកកាន់បព្វជិតភាព ដើម្បីស្វែងរកវិវរណៈផ្ទាល់ខ្លួន និងរៀនពីរបៀប ដើម្បីស្គាល់សេចក្ដីពិតដោយខ្លួនយើង តាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធពិត ។

សូមឲ្យយើងស្វែងរកពន្លឺនៃការបំផុតគំនិតផ្ទាល់ខ្លួនដោយយកចិត្តទុកដាក់ ។ ចូរយើងទូលអង្វរព្រះអម្ចាស់ដើម្បីប្រទានដល់គំនិត និងព្រលឹងរបស់យើងនូវផ្កាភ្លើងនៃសេចក្ដីជំនឿដែលនឹងអាចឲ្យយើងទទួល និងទទួលស្គាល់ការបម្រើដ៏ទេវភាពពីព្រះវិញ្ញាណបរិសុទ្ធចំពោះស្ថានភាព ឧបសគ្គ និងកាតព្វកិច្ចបព្វជិតភាពជាក់លាក់របស់យើង ។

**ទីបី ៖ ស្វែងរកអំណរនៅក្នុងការបម្រើបព្វជិតភាព**

អំឡុងពេលខ្ញុំមានអាជីពជាអ្នកបើកយន្តហោះ ខ្ញុំមានឱកាសដើម្បីពិនិត្យ និងហ្វឹកហ្វឺនដល់អ្នកបើកយន្តហោះផ្សេងទៀត ។ ចំណែកនៃការងារនេះគឺត្រូវហ្វឹកហ្វឺន និងសាកល្បងអ្នកបើកយន្តហោះដែលមានបទពិសោធន៍ ដើម្បីប្រាកដថា ពួកគេមានចំណេះដឹង និងជំនាញចាំបាច់ ដើម្បីបើកយន្តហោះធុនធំទាំងនោះដោយសុវត្ថិភាពល្អ ។

ខ្ញុំឃើញថាមានអ្នកបើកយន្តហោះជាច្រើន ទោះជាមានជំនាញបើកបរជាច្រើនឆ្នាំក្តី ក៏នៅមានចិត្តអំណររំភើប ពេលហោះចូលទៅក្នុងបរិយាកាស ចេញពីផែនដី ហើយហោះកាត់មេឃ ដោយស្លាបពណ៌ប្រាក់ » ។ [13] ពួកគេចូលចិត្តសម្លេងខ្យល់ប៉ប្រះ សម្លេងគ្រហឹមនៃម៉ាស៊ីនដ៏មានអានុភាព អារម្មណ៍នៃ « ការនៅជាមួយនឹងខ្យល់ និងមេឃងងឹត និងហ្វូងតារានៅខាងមុខ » ។ [14] សន្ទុះចិត្តរបស់ពួកគេគឺទំនាក់ទំនងគ្នា ។

ក៏មានមួយចំនួនដែលហាក់ដូចជាគ្រាន់តែឆ្លងកាត់ចលនា ។ ពួកគេបានគ្រប់គ្រងប្រព័ន្ធ ហើយគ្រប់គ្រងយន្តហោះ ប៉ុន្តែនៅតាមផ្លូវ ពួកគេមិនបានរីករាយនឹងការហោះហើរ « ដែលមើលមិនឃើញបក្សី ឬ សត្វឥន្ទ្រីហោះហើរ » នោះទេ ។ 15 ពួកគេបានបាត់បង់អារម្មណ៍អស្ចារ្យ ពេលព្រះអាទិត្យរះឡើង ភាពស្រស់ស្អាតនៃការបង្កបង្កើតរបស់ព្រះ នៅពេលពួកគេហោះហើរកាត់សមុទ្រ និងទ្វីបនានា ។ បើសិនជាពួកគេបំពេញតាមតម្រូវការជាផ្លូវការ ខ្ញុំធ្វើការបញ្ជាក់ឡើងវិញចំពោះពួកគេ ប៉ុន្តែស្របពេលជាមួយគ្នានោះ ខ្ញុំសោកស្ដាយចំពោះពួកគេ ។

អ្នកគួរសួរខ្លួនឯងថាតើអ្នកកំពុងតែប្រើអារម្មណ៍ ក្នុងនាមជាអ្នកកាន់បព្វជិតភាព -- ដោយធ្វើនូវអ្វីដែលបានរំពឹងទុក ប៉ុន្តែមិនទទួលបទពិសោធន៍នូវក្តីអំណរដែលគួរតែជារបស់អ្នកមែនទេ ។ ការកាន់បព្វជិតភាព ផ្តល់ឱកាសយ៉ាងច្រើនដល់យើង ដើម្បីទទួលអារម្មណ៍អំណរ ដែលអាំម៉ូនបានបង្ហាញ ៖ « តើយើងមិនមានហេតុដ៏ធំនឹងអររីករាយទេឬអី ? ... យើងជាគ្រឿងឧបករណ៍ នៅក្នុងព្រះហស្តទ្រង់ ដែលធ្វើកិច្ចការដ៏មហិមា និង
អស្ចារ្យនេះ ។ ហេតុដូច្នេះហើយ ចូរយើងអួត ...ក្នុងព្រះអម្ចាស់ មែនហើយ យើងនឹងអររីករាយ » ។ [16]

បងប្អូនប្រុស សាសនារបស់យើង គឺជាសាសនាប្រកបដោយអំណរ ! យើងទទួលពរខ្លាំងបំផុត ដើម្បីកាន់បព្វជិតភាពរបស់ព្រះ ! នៅក្នុងគម្ពីរទំនុកតម្កើង យើងអានថា « មានពរហើយ សាសន៍ណាដែលស្គាល់សម្លេងរីករាយនោះ ៖ ឱព្រះយេហូវ៉ាអើយ គេដើរនៅក្នុងពន្លឺនៃព្រះភក្ត្ររបស់ទ្រង់ » ។ [17] យើងអាចទទួលបទពិសោធន៍នៃក្តីអំណរធំជាង បើសិនជាយើងស្វែងរក ។

ជាញឹកញាប់ណាស់ យើងមិនបានទទួលបទពិសោធន៍នូវការរីករាយ មកពីអត្ថប្រយោជន៍នៃការបម្រើបព្វជិតភាពជាប្រចាំ ។ ជួនកាល ភារកិច្ចទាំងឡាយហាក់ដូចជាបន្ទុក ។ ចូរយើងកុំឆ្លងកាត់ជីវិតនៅក្នុងពាក្យបីម៉ាត់ ៖ នឿយហត់ ព្រួយបារម្ភ និងការអ៊ូរទាំ ។ យើងរស់នៅក្រោមឯក -សិទ្ធិរបស់យើង នៅពេលយើងបណ្តោយឲ្យភាពខ្វល់ខ្វាយខាងលោកិយ រារាំងយើងពីក្តីអំណរដ៏ច្រើន ដែលកើតចេញមកពីការបម្រើបព្វជិតភាពដ៏ស្មោះត្រង់ និងមានការលះបង់ ជាពិសេសនៅក្នុងគេហដ្ឋានរបស់យើង ។ យើងរស់នៅក្រោមពីឯកសិទ្ធិរបស់យើង នៅពេលយើងមិនបានទទួលទានសុភមង្គល សេចក្តីសុខសាន្ត និងសេចក្តីអំណរដែលព្រះបានប្រទានឲ្យយ៉ាងច្រើនបរិបូរដល់អ្នកបម្រើបព្វជិតភាពដ៏ស្មោះត្រង់នោះ ។

យុវជន បើសិនជា អ្នកយល់ថាការមកកាន់ព្រះវិហារមុនម៉ោង ដើម្បីជួយរៀបចំសាក្រាម៉ង់ ជាការងារពិបាកជាងការទទួលបានពរជ័យ នោះខ្ញុំសូមអញ្ជើញអ្នកឲ្យគិតអំពីអត្ថន័យនៃពិធីពិសិដ្ឋនេះចំពោះសមាជិកក្នុងវួដ ដែលប្រហែលជាមានបញ្ហានៅក្នុងសប្តាហ៍នោះ ។ បងប្អូនប្រុស បើសិនជាការខិតខំក្នុងការបង្រៀនតាមផ្ទះរបស់អ្នក មើលទៅពុំមានឥទ្ធិពលមកលើអ្នក នោះខ្ញុំសូមអញ្ជើញអ្នកឲ្យមើលដោយកែវភ្នែកនៃសេចក្តីជំនឿថា ការទៅសួរសុខទុក្ខពីអ្នកបម្រើរបស់ព្រះអម្ចាស់អាចធ្វើអ្វីខ្លះសម្រាប់គ្រួសារមួយដែលមានបញ្ហាជាច្រើនដែលមើលមិនឃើញ ។ ពេលអ្នកចាប់យកសក្តានុពលដ៏ទេវភាពនៃការបម្រើបព្វជិតភាពអ្នក នោះព្រះវិញ្ញាណនៃព្រះនឹងបំពេញក្នុងដួងចិត្ត និងគំនិតរបស់អ្នក វានឹងភ្លឺនៅក្នុងកែវភ្នែក និងផ្ទៃមុខរបស់អ្នក ។ ក្នុងនាមជាអ្នកកាន់បព្វជិតភាព ចូរយើងកុំរីងរូស ចំពោះភាពអស្ចារ្យ ហើយសូមស្ញើចចំពោះអ្វីដែលព្រះអម្ចាស់បានប្រគល់ដល់យើង ។

**សេចក្តីបញ្ចប់**

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ សូមឲ្យយើងស្វែងរកដោយព្យាយាមក្នុងការរៀនគោលលទ្ធិនៃបព្វជិតភាពបរិសុទ្ធ សូមឲ្យយើងពង្រឹងដល់ទីបន្ទាល់របស់យើងមួយបន្ទាត់ម្តងៗតាមរយៈការទទួលវិវរណៈពីព្រះវិញ្ញាណ សូមឲ្យយើងរកឃើញក្តីអំណរពិត នៅក្នុងការបម្រើបព្វជិតភាពប្រចាំថ្ងៃ ។ នៅពេលយើងធ្វើរឿងទាំងនេះ យើងនឹងចាប់ផ្តើមអនុវត្តតាមសក្តានុពល និង ឯកសិទ្ធិទាំងឡាយក្នុងនាមជាអ្នកកាន់បព្វជិតភាព ហើយយើងនឹង អាច « ធ្វើគ្រប់ទាំងអស់បានដោយសារព្រះគ្រីស្ទ ដែលទ្រង់ចម្រើនកម្លាំងដល់ [ យើង ] » ។ [18]

ខ្ញុំសូមថ្លែងទីបន្ទាល់អំពីការណ៍នេះ ក្នុងនាមជាសាវកមួយរូបរបស់ព្រះអម្ចាស់ ហើយសូមបន្សល់ទុកពរជ័យរបស់ខ្ញុំនឹងអ្នករាល់គ្នា ក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ


1. យ៉ូសែប ស្ម៊ីធ នៅក្នុង History of the Church 3:386 ។

2. គោលលទ្ធិ និង សេចក្តីសញ្ញា 84:19 ។

3.គោលលទ្ធិ និង សេចក្តីសញ្ញា 84:20 ។

4. គោលលទ្ធិ និង សេចក្តីសញ្ញា 84:34 ។

5.គោលលទ្ធិ និង សេចក្តីសញ្ញា 84:34 ។

6. គោលលទ្ធិ និង សេចក្តីសញ្ញា 84:38 ។

7. សូមមើល យ៉ាកុប 1:22 ។

8.យ៉ូសែប ស្ម៊ីធ នៅក្នុង History of the Church 4:207 ។

9. នីហ្វៃ 2 28:30 ។

10. គោលលទ្ធិ និង សេចក្តីសញ្ញា 88:40 ។

11. គោលលទ្ធិ និង សេចក្តីសញ្ញា 50:24 ។

12. គោលលទ្ធិ និង សេចក្តីសញ្ញា 93:19 ។

13. យ៉ូហាន ហ្គីលីសពី ជុញ្ញ័រ « High Flight » នៅក្នុង Diane Ravitch, ed *The American Reader*: Words That Moved a Nation ( ឆ្នាំ 2000 ) ទំព័រ 486 ។

14. រីឆាត បាច Stranger to the Ground ( ឆ្នាំ 1963 ) ទំព័រ 9 ។

15. ម៉ាគី « High Flight » 486 ។
16. អាលម៉ា 26:13, 15-16 ។
17. ទំនុកដំកើង 89:15,16 ។
18. ភីលីព 4:13 ។